ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១១ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០០៧ | តម្លៃ ១.៥០០រ

# បណ្ណកម្មសិទ្ធិដីនៅទីក្រុង ឥណទានផ្លូវការ និងវិនិយោគលើ សហគ្រាសធុនតូច និងមធ្យម

Brett Ballard និង ភីម រុនស៊ីណារិទ្ធិ ពិភាក្សាពីទំនាក់ទំនងរវាង ប័ណ្ណកម្មសិទ្ធិដី ឥណទានមានតំលៃថោកអាចប្រើប្រាស់បាន និងវិនិយោគលើ សហគ្រាសធុនតូច និងមធ្យម (SME) ក្នុងតំបន់ទីក្រុងចំនួន ៣ នៅកម្ពុជា ។*


សហគ្រាសធុនតូចនិងមធ្យមមួយកន្លែង ផលិតទ្វារ និងបង្អួចធ្វើពីដែក នៅតាមផ្លូវ ២៧១ ក្រុងភ្នំពេញ

អត្ថបទនេះពិភាក្សាពីទំនាក់ទំនងរវាង ប័ណ្ណកម្មសិទ្ធិដី ឥណទានមានតំលៃថោកអាចប្រើប្រាស់បាន និងវិនិយោគលើសហគ្រាសធុនតូច និងមធ្យម (SME)[១] ក្នុងតំបន់ទីក្រុងចំនួន ៣ នៅកម្ពុជា ។ ទិន្នន័យប្រមូលបាននៅចុងឆ្នាំ២០០៥ ព្រមទាំងអង្កេតមូលដ្ឋានរបស់ CDRI លើការផ្តល់ប័ណ្ណកម្មសិទ្ធិដី នៅតំបន់ទីក្រុង បានបង្ហាញថា SMEs អាចជាប្រភពដ៏សំខាន់នៃការងារនៅភ្នំពេញ ក្រុងសៀមរាប និង សេរីសោភ័ណ្ឌ (បន្ទាយមានជ័យ) ។ ប័ណ្ណកម្មសិទ្ធិដី មានផលប៉ះពាល់យ៉ាងច្រើនលើចំនួនការងារ បើពិនិត្យពីកំលាំងវា ក្នុងការជួយជំរុញកំណើនវិនិយោគការបើកអាជីវកម្មថ្មី រឺការពង្រីកអាជីវកម្មដោយបង្កើតអារម្មណ៍កាន់កាប់ដីមានសុវត្ថិភាព និងជួយបង្កើនលទ្ធភាពទទួលបានឥណទានមានតំលៃថោកអាចប្រើប្រាស់បាន ។

ការសន្មត និងការទស្សទាយពីអត្ថប្រយោជន៍រំពឹងទុកនៃកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដី ផ្អែកជាសំខាន់លើទ្រឹស្តីនៃកម្មសិទ្ធិអចលនទ្រព្យ ដែលចងភ្ជាប់សន្ទះចិត្តធ្វើវិនិយោគ ទៅនឹងសុវត្ថិភាពកាន់កាប់ដី ។ អំណះអំណាងជាមូលដ្ឋាន គឺប្រជាជនតែងចង់វិនិយោគលើសកម្មភាពមានផលិតភាពខាងសេដ្ឋកិច្ច បើសិនមានទំនុកចិត្តថាខ្លួនគេ រឺអ្នកស្នងមរតករបស់ពួកគេ នឹងទទួលបានអត្ថប្រយោជន៍ពីវិនិយោគនោះ (Brando and Feder 1996; Barzel 1997) ។ ទាក់ទិននឹងការកាត់បន្ថយភាពក្រីក្រ លោក de Soto (2000) បានរំលែកថា អ្នកក្រក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក៏មានទ្រព្យសកម្មច្រើនដែរ ទោះបីក្នុងទំរង់ជា "ទុនងាប់"[២] ដែលពិបាកប្រើប្រាស់ធ្វើវិនិយោគក្តី ។ ដូច្នេះរដ្ឋាភិបាលគួរផ្តល់កម្មសិទ្ធិលើអចលនទ្រព្យ ក្នុងទំរង់ជាប័ណ្ណកម្មសិទ្ធិស្របច្បាប់ ដែលអ្នកក្រអាចយកទៅដាក់ធានា ដើម្បីទទួលបានឥណទានសំរាប់វិនិយោគលើការកែលំអផ្ទះសំបែង SMEs រឺសកម្មភាពផលិតផ្សេងៗ ។

យោងតាមអំណះអំណាងខាងលើ ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិផ្លូវការដើម្បីគ្រប់គ្រងការកាន់កាប់ដី ត្រូវតែចាត់ទុកថាជាចំណែកមួយនៃវិធីសាស្ត្រផ្អែកលើទីផ្សារដើម្បីអភិវឌ្ឍន៍តំបន់ទីក្រុង នៅក្នុងបរិបទមួយដែលមានបទប្បញ្ញត្តិផ្លូវការជាច្រើន។ បទប្បញ្ញត្តិទាំងនេះរួមមាន របៀបរបបផ្តល់

* លោកបណ្ឌិត Brett Ballard ជាទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់ និងលោក ភីម រុនស៊ីណារិទ្ធិ ជាអ្នកស្រាវជ្រាវ នៅ CDRI ។ អត្ថបទនេះ ផ្អែកលើអង្កេតមូលដ្ឋានរបស់ CDRI លើការចុះបញ្ជីដីធ្លី ក្នុងកម្មវិធីចុះបញ្ជីដីធ្លីកម្ពុជា ។

## មាតិកា

ប័ណ្ណកម្មសិទ្ធិដីនៅទីក្រុង ........ ១
បញ្ហាប្រឈមក្នុងការគ្រប់គ្រងធនធានទឹក........ ៥
ពាណិជ្ជកម្មកសិកម្មនៅមហាអនុតំបន់មេគង្គ ........ ៩
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៣
— ស្ថានភាពក្នុងប្រទេស ........ ១៥
— សន្ទស្សន៍សេដ្ឋកិច្ច ........ ១៨
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន វបសអ_CDRI ........ ២០

**តារាង១: ការងារក្នុង SMEs គិតតាមទីតាំង**

| ទីតាំង | ចំនួនគ្រួសារ | ពលករអចិន្ត្រៃយ៍ | | ពលករជួលតាមថ្ងៃ | | សមាជិកគ្រួសារ | | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | | ចាប់ផ្ដើម | បច្ចុប្បន្ន | ចាប់ផ្ដើម | បច្ចុប្បន្ន | ចាប់ផ្ដើម | បច្ចុប្បន្ន | ចាប់ផ្ដើម | បច្ចុប្បន្ន |
| ភ្នំពេញ | 436 | 239 | 310 | 59 | 125 | 739 | 929 | 1037 | 1364 |
| សៀមរាប | 162 | 53 | 87 | 148 | 160 | 353 | 365 | 554 | 612 |
| សេរីសោភ័ណ្ឌ | 241 | 53 | 92 | 36 | 46 | 477 | 511 | 566 | 649 |

ឥណទានផ្លូវការ និងទីផ្សារអចលនទ្រព្យមានច្បាប់គ្រប់គ្រងល្អ (ឧ. ផែនការមេកំណត់ការប្រើប្រាស់ដី ការដាក់អនុវត្តន៍បទប្បញ្ញត្តិបែងចែកតំបន់) ដែលជួយទ្រទ្រង់ឱ្យបរិយាកាសអាជីវកម្មមានលក្ខណៈរឹងប៉ឹងច្បាស់លាស់ ។

អង្កេតមូលដ្ឋានលើការផ្ដល់ប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុង បានធ្វើឡើងពីខែតុលា-ធ្នូ ២០០៥ ។ ដោយឡែកនៅក្រុងភ្នំពេញ បានធ្វើអង្កេតលើ ១៦៦៣គ្រួសារ ក្នុងខ័ណ្ឌបីនៃខ័ណ្ឌទាំងបួនក្នុងក្រុង និងក្នុងខ័ណ្ឌទាំងបីនៅជាយក្រុង ។ ក្នុងនេះមាន ៤៣៩គ្រួសារ (២៨,៤%) រាយការណ៍ថាជាកម្មសិទ្ធិករលើ ៤៧០ SMEs រឺប្រហែល ១,០៩ SMEs ក្នុងមួយគ្រួសារ ។ នៅស្រុកសៀមរាប បានធ្វើសំភាសន៍លើ ៥៣៦គ្រួសារ ក្នុងឃុំសាលាកំរើក ដែលស្ថិតនៅតំបន់ទីក្រុង និងឃុំសៀមរាប ដែលស្ថិតនៅតំបន់ជាយក្រុង ។ ក្នុងនេះមាន ១៦៤គ្រួសារ រាយការណ៍ថា ជាកម្មសិទ្ធិករលើ ១៩២ SMEs ដូច្នេះមានគ្រួសារ ៣០,៦% ធ្វើជាម្ចាស់ SMEs ដោយគ្រួសារនីមួយៗជាមធ្យមមាន ១,១៧ SMEs ។ នៅក្នុង និងនៅជុំវិញក្រុងសេរីសោភ័ណ្ឌ បានធ្វើសំភាសន៍លើ ៥០៧គ្រួសារ នៅ ៣ឃុំ គឺ កំពង់ស្វាយ ព្រះពន្លា និង អូរអំបិល ដោយមាន ២៤១គ្រួសារ (២៨,៤%) រាយការណ៍ថាកំពុងដំណើរការ ២៨៥ SMEs រឺប្រហែល ១,១៨ SMEs ក្នុងមួយគ្រួសារ ។

តារាង១ បង្ហាញថា នៅតំបន់ទីក្រុងទាំងបី ការងារក្នុង SMEs បានកើនឡើងចាប់តាំងពីពេលធ្វើអាជីវកម្មមក ។ នៅភ្នំពេញចំនួនការងារកើនពី ២,៣៨ នៅពេលចាប់ផ្ដើម រហូតដល់ ៣,១៣ ជាមធ្យម ក្នុងមួយអាជីវកម្ម ហើយនៅសៀមរាប កើនពី ៣,៤២ ដល់ ៣,៧៨ ក្នុងមួយអាជីវកម្ម ។ នៅសេរីសោភ័ណ្ឌ វាកើនពី ២,៣៥ ដល់ ២,៦៩ ។ យោងតាម និយមន័យ SMEs ដែលផ្អែកលើចំនួនបុគ្គលិក ស្ទើរតែគ្រប់អាជីវកម្មនៅក្នុងអង្កេតនេះសុទ្ធតែជាធុនតូច ហើយមានតិចតួចណាស់ដែលអាចចាត់ទុកជាធុនមធ្យម ។ បើសន្មតថា ចំនួនគំរូតាងអង្កេតនេះអាចតំណាងឱ្យប្រជាជនទាំងអស់បាន ការអភិវឌ្ឍន៍ SMEs អាចបង្កើតការងារបានច្រើនគួរសម ។

ជាការសំខាន់គួរពិនិត្យដែរថា តើអាជីវកម្មធុនតូចនានា បានទុនមកពីណា ។ តារាង២ បង្ហាញថា នៅភ្នំពេញ ទុន ៩១,៩% បានពី "ប្រភពផ្ទាល់ខ្លួន" ។ នៅសៀមរាប និង សេរីសោភ័ណ្ឌ ក៏មានទុនប្រភពផ្ទាល់ខ្លួន ក៏រិតខ្ពស់ដែរ ដល់ទៅ ៨៦,១% និង ៨៥,០% ។ នៅតំបន់ទីក្រុងទាំង ៣ អ្នកចងការប្រាក់ហាក់ដូចគ្មានតួនាទីអ្វីទេ ក្នុងការផ្ដល់ទុនឱ្យ SMEs ហើយមានកំចីតែមួយចំនួនតូចប៉ុណ្ណោះដែលបានមកពីធនាគារពាណិជ្ជ ។

ការសង្កេតឃើញខាងលើ បានបំផុសសំនួរថា ហេតុអ្វីមានម្ចាស់អាជីវកម្មធុនតូចច្រើនគ្នាបែបនេះ ដែលបន្តពឹងផ្អែកលើទុនប្រភពផ្ទាល់ខ្លួន រឺរបស់ក្រុមគ្រួសារ ដើម្បីបើកអាជីវកម្មថ្មី បន្តដំណើរការ រឺពង្រីកសកម្មភាព ។ ក្នុងការសិក្សាកាលពីមុន លោក កង ច័ន្ទតារ៉ាវ័ត្ត (២០០៥) បានសន្និដ្ឋានថា ផ្ទុយពីគោលគំនិតក្នុងទ្រឹស្តីសេដ្ឋកិច្ចបែបបុរាណ ប្រព័ន្ធធនាគារដែលអភិវឌ្ឍបានល្អនោះ ប្រហែលមិនសូវចាំបាច់ទេសំរាប់ការបើកអាជីវកម្មថ្មី ។ សុវត្ថិភាពនៃកិច្ចសន្យាលើការខ្ចីប្រាក់ពីស្ថាប័នផ្លូវការ អាចប្រៀបផ្ទឹមគ្នាបានជាមួយទំនុកចិត្តកំរិតខ្ពស់រវាងបុគ្គល នៅក្នុងការខ្ចីបុលក្រៅផ្លូវការ ។

កត្តាមួយទៀតដែលអាចផុសឡើង គឺវិនិយោគិននានាច្រើនតែមិនច្បាស់លាស់ក្នុងចិត្ត រឺមិនសូវទុកចិត្តថា អាជីវកម្មរបស់ខ្លួនអាចរស់រានបាន ។ ឧទាហរណ៍ នៅភ្នំពេញក្នុងចំណោម SMEs ដែលបានឆ្លើយសំភាសន៍ប្រាប់ថា មិនបានខ្ចីប្រាក់ គឺមាន ៨១% បញ្ជាក់ថា ខ្លួនឯកភាពជាខ្លាំង រឺឯកភាពដែរលើហេតុផលថា ផលចំណេញរំពឹងទុកនៃអាជីវកម្ម អាចបានតិចជាងចំណាយការប្រាក់បង់លើកំចី ។ នៅសៀមរាប អ្នកគិតដូច្នេះមានដល់ទៅ ៧៥,៥% ។

លោក កង ពិនិត្យឃើញថា ក្នុងចំណោម ៦៤៨ SMEs ដែលបានឆ្លើយសំភាសន៍ មាន ៧០,១% បានចាត់ទុកកង្វះទុនថា ជាកំហិតធំបំផុតលើការពង្រីកអាជីវកម្មសំរាប់សហគ្រាសគ្រប់ធុន គ្រប់ប្រភេទ និង នៅគ្រប់ទីកន្លែង ។ ដោយសារកង្វះទុន ហាក់ដូចជាជាប់ទាក់ទងនឹង "ការរកចំណេញមិនបានគ្រប់គ្រាន់" លោក កង យល់ឃើញថា ការកសាងប្រព័ន្ធធនាគារឱ្យរឹងប៉ឹង និងកិច្ចសន្យាមានសុវត្ថិភាពល្អខាងផ្លូវច្បាប់ អាចជាកត្តាគន្លឹះសំរាប់ដោះស្រាយបញ្ហាវិនិយោគបែបនេះ ។ ដូច្នេះមានការឯកភាពជាទូទៅថា ការកែលំអលទ្ធភាពទទួលបានឥណទានផ្លូវការ អាច និងគួរមានតួនាទីសំខាន់ថែមទៀតក្នុងការផ្ដល់ទុនសំរាប់វិនិយោគលើទ្រព្យសកម្មជាប់លាប់ ។

សំរាប់អាជីវកម្មបើកថ្មី និងពង្រីកបន្ថែម តំរូវការរបស់សំរាប់ដាក់ធានា គឺជាកំហិតធំមួយ ។ ក្នុងចំណោម ១៣៧ SMEs ដែលសុំខ្ចីប្រាក់ពីធនាគារ លោក កង រកឃើញថា មាន ៥២% បានទទួលការបដិសេធ ក្នុងនេះ ៦០ អាជីវកម្ម ត្រូវគេបដិសេធដោយសារខ្វះរបស់ដាក់ធានា ។ ក្នុងការសិក្សាពី

**តារាង២ : ប្រភពទុនសំរាប់ចំណាយធ្វើអាជីវកម្ម និងចំណាយក្នុងជីវភាពរស់នៅ**

| ទីតាំង | ប្រភពផ្ទាល់ខ្លួន | | គ្រួសារ | | អ្នកចងការប្រាក់ | | ធនាគារពាណិជ្ជ | | ផ្សេងទៀត | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | |
| ភ្នំពេញ | 440 | 91.9 | 29 | 6.1 | 1 | 0.2 | 4 | 0.8 | 5 | 1.0 | 479 |
| សៀមរាប | 167 | 86.1 | 16 | 8.2 | 0 | 0 | 9 | 4.6 | 2 | 1.0 | 194 |
| សេរីសោភ័ណ្ឌ | 256 | 85.0 | 26 | 8.6 | 0 | 0 | 7 | 2.3 | 12 | 4.1 | 301 |

ការផ្ដល់ប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុង មាន ៤៤,២% នៃ SMEs នៅភ្នំពេញ បាន "ឯកភាពខ្លាំងក្លា" និង "ឯកភាពដែរ" ថា តំរូវការរបស់ដាក់ធានា បានរារាំងពួកគេក្នុងការស្វែងរកកំចីពាណិជ្ជកម្ម ។ មានប្រហែល ៣០,៥% បាន "ឯកភាពខ្លាំងក្លា" រឺ "ឯកភាពដែរ" ថា ពួកគេទទួលការបដិសេធពីព្រោះខ្វះរបស់ដាក់ធានា ។ នៅសៀមរាប មាន ៤៥,១% បាន "ឯកភាពខ្លាំងក្លា" រឺ "ឯកភាពដែរ" ថា តំរូវការរបស់ដាក់ធានា បានរារាំងពួកគេក្នុងការស្វែងរកកំចីពាណិជ្ជកម្ម ។

ស្ថានភាពខាងលើ ហាក់ដូចបានប្រែប្រួលហើយ ។ យោងតាមការពិភាក្សានាពេលថ្មីៗជាមួយមន្ត្រីធនាគារ ចំនួនពាក្យសុំខ្ចីប្រាក់ និងការអនុមតិ បានកើនច្រើនណាស់ក្នុងឆ្នាំកន្លងទៅ ជាពិសេសសំរាប់ការពង្រីកអាជីវកម្ម រួមទាំង SMEs ។ មានសេចក្ដីរាយការណ៍ជាច្រើនបញ្ជាក់ថា វិនិយោគិននៅតែរារែកទៅខ្ចីប្រាក់ពីធនាគារដើម្បីបើកអាជីវកម្មថ្មី ពីព្រោះពួកគេមិនសូវទុកចិត្តលើផលចំណេញបានពីវិនិយោគ ។ ដូច្នេះការបើកអាជីវកម្មថ្មីនៅតែបន្តពឹងផ្អែកជាសំខាន់លើទុនផ្ទាល់ខ្លួន រឺខ្ចីពីសាច់ញាតិ មិត្តភក្ដិ ។ ប៉ុន្តែនៅពេលអាជីវកម្មមានដំណើរការ ហើយអាជីវករមើលឃើញប្រាក់ចំណូលហូរចូលយ៉ាងទៀងទាត់ និងអាចទស្សទាយបាន ពួកគេហាក់ដូចកាន់តែហ៊ានទៅខ្ចីប្រាក់ពីធនាគារពាណិជ្ជ យកមកពង្រីកអាជីវកម្ម ។

ការប្រែប្រួលឥរិយាបទក្នុងការទៅខ្ចីប្រាក់ពីធនាគារពាណិជ្ជ ហាក់ដូចទើបកើតមានថ្មីៗនេះទេ ។ នៅពេលបរិយាកាសធ្វើអាជីវកម្មនៅកម្ពុជាប្រែប្រួលប្រសើរឡើង ហើយវិនិយោគិនក៏កាន់តែទុកចិត្តលើវិស័យធនាគារ និន្នាការមានកំណើនតំរូវការឥណទានសំរាប់គោលដៅផ្សេងៗ ប្រហែលនឹងបន្តទៅមុខទៀត ។ ដោយសារធនាគារត្រូវការ "បួងរឹង" ក្នុងការផ្ដល់កំចីដូច្នេះប័ណ្ណកម្មសិទ្ធិដី ប្រហែលអាចជួយបង្កើនកំចីសំរាប់ដោះស្រាយចំណាយប្រើប្រាស់ និងធ្វើអាជីវកម្ម ។ គួរកត់សំគាល់ជាសំខាន់ថា កំណើនបែបនេះ អាចមិនមែនផុសចេញពីប័ណ្ណកម្មសិទ្ធិដីតែមួយមុខនោះទេ ប៉ុន្តែមានកត្តាជាច្រើន ដែលគួបផ្សំគ្នាបង្កើតបានជាវដ្ដមួយដ៏ប្រសើរនៃការអភិវឌ្ឍន៍ និងការរីកចំរើន ។ កត្តាទាំងនេះមានជាអាទិ៍ បទពិសោធន៍/ជំនាញ (គឺ សហគ្រិនភាព) សុវត្ថិភាព/ស្ថិរភាពនយោបាយ ធនាគារដែលចង់និងចេះផ្ដល់កំចី (គឺ ការផ្គត់ផ្គង់ឥណទាន) និងប្រជាជនមានទំនុកចិត្តលើស្ថាប័នធនាគារ ។ ការអភិវឌ្ឍន៍ទីផ្សារឥណទាន និងវិស័យអាជីវកម្ម ហាក់ដូចឈរលើកត្តាដូចគ្នាជាច្រើន ក្នុងរឿងទំនុកចិត្តលើស្ថាប័ន ។ នៅពេលកត្តាទាំងនេះកើតមានជាក់ស្ដែង និងដំណើរការមានប្រសិទ្ធភាពល្អ វាជួយឱ្យសហគ្រិននានា អាចទស្សទាយកាន់តែត្រឹមត្រូវពីផលចំណេញលើវិនិយោគ ។

ក្នុងអង្កេតលើការផ្ដល់ប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុង មានភស្តុតាងជាច្រើន ដែលហាក់ដូចបញ្ជាក់គាំទ្រដល់ការសង្កេតឃើញពីការផ្លាស់ប្ដូរឥរិយាបទទាក់ទិននឹងកំចីពីធនាគារពាណិជ្ជ ។ តារាង ៣ មានចុះសង្ខេបពីកំចីជាប់ទាក់ទិនអាជីវកម្ម និងប្រភពរបស់វា ។ នៅភ្នំពេញ ក្នុងចំណោម ៥០២កំចី ដែលគេរាយការណ៍ថា បានកើតមាននៅចន្លោះពេលរវាងការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ២០០៣ នឹងចុងឆ្នាំ២០០៥ គឺមាន ១៨០ (រឺ ៣៥,៦%) ជាកំចីសំរាប់បើកអាជីវកម្មថ្មី ដោះស្រាយដំណើរការ និងពង្រីកអាជីវកម្ម ។ នៅសៀមរាប កំចីសំរាប់បំរើអាជីវកម្មមាន ៣៨,៥% ហើយនៅសេរីសោភ័ណ្ឌ មាន ៣៣,៨% ។ ចំណុចគួរយកចិត្តទុកដាក់ គឺសំរាប់កំចីបំរើអាជីវកម្ម ធនាគារអេស៊ីលីដាផ្ដល់បាន ៤១,១% នៅភ្នំពេញ ៤៨,០% នៅសៀមរាប និង ៣៦,៧% នៅសេរីសោភ័ណ្ឌ ។ បើគិតទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ផង ស្ថាប័នផ្ដល់កំចីផ្លូវការហាក់ដូចដើរតួនាទីសំខាន់ ក្នុងការផ្ដល់ទុនសំរាប់សកម្មភាពអាជីវកម្ម ។

ស្របនឹងកំណើនយ៉ាងទៀងទាត់ជារៀងរាល់ឆ្នាំនៃចំនួនកំចីពីគ្រប់ប្រភពនៅក្នុងតំបន់ទីក្រុងទាំង ៣ ចំនួនកំចីពីប្រភពផ្លូវការ (គឺ MFIs និងធនាគារពាណិជ្ជ) ក៏កើនឡើងដែរ ។ នៅភ្នំពេញ កំចីពីប្រភពផ្លូវការមាន ៣៧,៥% នៅឆ្នាំ២០០៣ និង ៤១,៧% នៅឆ្នាំ២០០៥ ។ នៅសៀមរាប និងសេរីសោភ័ណ្ឌ ថ្វីបើចំនួនកំចីកើនឡើងជារៀងរាល់ឆ្នាំក្ដី ប៉ុន្តែចំនួនកំចីផ្លូវការគិតជាភាគរយបានថយចុះ ។ នៅសៀមរាប វាថយចុះពី ៥៤,១% នៅ

**តារាង៣: ប្រភពកំចីសំរាប់សកម្មភាពជាប់ទាក់ទិនអាជីវកម្ម**

| | សាច់ញាតិ | មិត្តភក្ដិ | អ្នកចងការប្រាក់ | NGO | MFI | អេស៊ីលីដា | សរុប |
|---|---|---|---|---|---|---|---|
| ភ្នំពេញ | 147 | 32 | 97 | 23 | 27 | 172* | 502* |
| *ចាប់បើកថ្មី* | 9 | 3 | 10 | 5 | 7 | 23 | 60 |
| *ធាតុចូល/ដំណើរការ* | 14 | 2 | 4 | 2 | 1 | 16 | 40 |
| *ពង្រីក* | 14 | 4 | 15 | 5 | 7 | 35 | 80 |
| សៀមរាប | 49 | 7 | 37 | 5 | 26 | 71 | 195 |
| *ចាប់បើកថ្មី* | 3 | 0 | 2 | 0 | 5 | 10 | 20 |
| *ធាតុចូល/ដំណើរការ* | 4 | 0 | 4 | 0 | 2 | 6 | 16 |
| *ពង្រីក* | 0 | 1 | 6 | 1 | 8 | 23 | 39 |
| សេរីសោភ័ណ្ឌ | 23 | 5 | 54 | 7 | 15 | 41 | 145 |
| *ចាប់បើកថ្មី* | 3 | 1 | 7 | 0 | 0 | 4 | 15 |
| *ធាតុចូល/ដំណើរការ* | 3 | 0 | 6 | 1 | 4 | 4 | 18 |
| *ពង្រីក* | 1 | 0 | 5 | 0 | 0 | 10 | 16 |

* តួលេខនេះមានបូកទាំង កំចីមួយរបស់ធនាគារកាណាឌីយ៉ាផង

ឆ្នាំ២០០៣ មកត្រឹម ៤៧,០% នៅឆ្នាំ២០០៥ ថ្វីបើចំនួនជាក់ស្តែងនៃកំចីបានកើនទ្វេជិតមួយជាពីរក្តី ។

ចំពោះតួលេខឥណទានទាក់ទិនអាជីវកម្ម និងតួលេខកំចីផ្តល់ឱ្យ SMEs គឺហាក់ដូចមិនរលូនគ្នាទេ ។ ទិន្នន័យលើកំចីអាជីវកម្ម បង្ហាញនូវកំណើនទឹកប្រាក់កំចីពីវិស័យផ្លូវការ ប៉ុន្តែទិន្នន័យ SME បង្ហាញថា វិស័យផ្លូវការមានតួនាទីតិចតួចណាស់ក្នុងការផ្តល់ទុនសំរាប់ការបើកអាជីវកម្មថ្មី កិច្ចដំណើរការ និងការពង្រីកសកម្មភាព ។ តួលេខមិនស៊ីគ្នានេះ អាចពន្យល់បានច្រើនយ៉ាង ។

ទី១ ទិន្នន័យលើកំចីទាំងអស់ មានរួមបញ្ចូលសកម្មភាពជាប់ទាក់ទិនអាជីវកម្មគ្រប់ប្រភេទ ទាំងតូច ទាំងធំ ក្នុងនេះមានខ្លះប្រើបុគ្គលិករហូតដល់ជាង ១០នាក់ ចំណែកឯទិន្នន័យលើ SMEs កត់ត្រាសឹងតែសុទ្ធសាធនូវសហគ្រាសធុនតូចដែលប្រើបុគ្គលិកតិចជាង ៥នាក់ ។ ជាទូទៅអាជីវកម្មធំៗតែងត្រូវការទុនច្រើនៗ ដូច្នេះក៏មានទឹកចិត្តជាងក្នុងការទៅខ្ចីប្រាក់ពីស្ថាប័នផ្លូវការ ព្រមទាំងមានលទ្ធភាពច្រើនជាង SMEs ដើម្បីសងការប្រាក់ក៏រិតខ្ពស់របស់ធនាគារពាណិជ្ជ ក៏ដូចជាសងបំណុលតាមតារាងពេលដ៏តឹងរ៉ឹង ។

ទី២ ទិន្នន័យលើឥណទាន គ្របដណ្តប់តែលើចន្លោះពេលពីការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ២០០៣ ដល់ចុងឆ្នាំ២០០៥ ចំណែកឯទិន្នន័យសំរាប់ SMEs គ្របដណ្តប់តាំងពីឆ្នាំ១៩៨០ ។ គួរចងចាំថា ទោះបីនៅដើមទសវត្សរ៍២០០០ហើយក្តី ក៏វិស័យធនាគារមិនទាន់ចូលរួមច្រើនទេក្នុងសកម្មភាពផ្តល់កំចី ។ ឧទាហរណ៍ ឯកសារមួយផ្សព្វផ្សាយនៅឆ្នាំ២០០៣ របស់កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) បានលើកពីហេតុផល ១៥យ៉ាងដែលធនាគារមិនបានផ្តល់កំចីឱ្យ SMEs រហូតមកដល់ពេលនោះ ។ អ្នកស្រាវជ្រាវ Keith Carpenter និង អ៊ូច ច័ន្ទតារានី (២០០៦) បានរកឃើញថា ហេតុផលចំបងមួយនៃការផ្តល់កំចីបែបស្ទាក់ស្ទើរនេះ គឺ ធនាគារមិនចង់ឱ្យខ្ចីតែម្តង ។ ដោយសារ SMEs ៦១,៨% នៅភ្នំពេញ និង ៦៤,៦% នៅសៀមរាប បានធ្វើអាជីវកម្មតាំងពីមុនឆ្នាំ២០០៣ ដូច្នេះទុនស្ទើរតែទាំងអស់សុទ្ធសឹងបានមកពីប្រភពផ្ទាល់ខ្លួន រឺសាច់ញាតិ ។

ទី៣ កត្តាដែលអាចសំខាន់ជាងគេ គឺ កំចីសឹងតែទាំងអស់ដែលគេរាយការណ៍ថាបានមកពីវិស័យពាណិជ្ជកម្ម សុទ្ធតែផ្តល់ដោយធនាគារអេស៊ីលីដាដែលមានសាខានៅពាសពេញប្រទេស ។ ជាក់ស្តែងមានតែកំចីមួយប៉ុណ្ណោះដែលបានមកពីធនាគារកាណាឌីយ៉ា ។ អេស៊ីលីដាមានប្រវត្តិជា NGO ខាងមីក្រូហិរញ្ញវត្ថុ និងមានរបៀបរបបផ្តល់កំចីផ្អែកទៅតាមគោលដៅខាងសង្គមកិច្ច គឺខុសពីធនាគារពាណិជ្ជឯទៀតៗនៅកម្ពុជា ។ បើសិនដកអេស៊ីលីដាចេញពីវិស័យធនាគារផ្លូវការ គេឃើញថាធនាគារពាណិជ្ជឯទៀតមិនបានផ្តល់កំចីទេ ទោះសំរាប់គោលដៅអ្វីក៏ដោយ រួមទាំងសកម្មភាពអាជីវកម្មផង ។ ដូច្នេះ ក្រៅពីកំចីមួយចំនួនតូចរាយការណ៍ដោយ MFIs សកម្មភាពអាជីវកម្មភាគច្រើន នៅតែផ្តល់ទុនដោយប្រភពក្រៅផ្លូវការ ក្នុងនេះមានទាំងអ្នកចងការប្រាក់ផងដែរ ។ រឿងនេះដូចគ្នាខ្លាំងណាស់នឹង SMEs ដោយទុនភាគច្រើនបានពីប្រភពផ្ទាល់ខ្លួន រឺសាច់ញាតិដែលជាទូទៅផ្តល់កំចីឱ្យដោយមិនយកការប្រាក់ រឺទាមទារឱ្យដាក់របស់ធានាឡើយ ។ មានតែអ្នកចងការប្រាក់ទេ ដែលយកការប្រាក់ ។ ដោយសារម្ចាស់ SMEs ហាក់បារម្ភច្រើនថា ចំណាយលើការប្រាក់វាឡើងខ្ពស់ជាងចំណូលអាចរកបាន ពួកគេតែងជៀសវាងមិនខ្ចីបុលពីអ្នកចងការប្រាក់ទេ ប៉ុន្តែមានអាជីវកម្មធំៗខ្លះ ហ៊ានខ្ចីពីប្រភពនេះ ។

សកម្មភាពឥណទានពាក់ព័ន្ធនឹងវិស័យធនាគារផ្លូវការ គឺឃើញមានគេរាយការណ៍ប្រាប់ច្រើនក៏ពិតមែន ប៉ុន្តែគេត្រូវពុះពារទៅមុខទៀតច្រើនណាស់មុននឹងវិនិយោគិន SMEs និងវិស័យធនាគារជាប្រពៃណីនេះ ទទួលស្គាល់គ្នាទាំងស្រុងទៅវិញទៅមក ។ ថ្វីបើការលំបាកទាក់ទិននឹងតំរូវការរបស់ធានាអាចដោះស្រាយបានមួយកំរិតធំដោយប្រើប័ណ្ណកម្មសិទ្ធិដីក្តី ប៉ុន្តែទិន្នន័យបង្ហាញច្បាស់ថា វិនិយោគិនត្រូវជួបកំហិតជាច្រើនទៀតដើម្បីទទួលបានកំចី ។ ដូចបានពិភាក្សាខាងលើ អត្រាចំណេញរបស់អាជីវកម្មធៀបនឹងអត្រាការប្រាក់មានសារៈសំខាន់ខ្លាំងណាស់ ។ ទោះបីអេស៊ីលីដា ក៏មានអត្រាការប្រាក់ខ្ពស់ណាស់ដែរ លើកំចីតូចៗនៅឆ្នាំ២០០៤-២០០៥ ។[៤] ដូច្នេះ ទោះបីប័ណ្ណកម្មសិទ្ធិដីអាចជួយបង្កើនលទ្ធភាពទទួលបានកំចីពាណិជ្ជកម្ម ដោយដើរតួជារបស់សំរាប់ដាក់ធានាក្តី ប៉ុន្តែគេត្រូវដោះស្រាយកំហិតជាច្រើនទៀត ទើបអាចប្រើប័ណ្ណនេះបានពេញលេញ ។ ប័ណ្ណកម្មសិទ្ធិដីអាចចាំបាច់ក៏ពិតមែន ប៉ុន្តែវាមិនគ្រប់គ្រាន់ទេសំរាប់ជំរុញកំណើនវិនិយោគដើម្បីបើកថ្មី និងពង្រីក SMEs ។

## សន្និដ្ឋាន

ថ្វីបើទិន្នន័យឥណទានបង្ហាញថា ពីឆ្នាំ២០០៣-២០០៥ ប្រជាជនបានបង្កើនការខ្ចីប្រាក់ពីវិស័យពាណិជ្ជកម្មសំរាប់គោលដៅផ្សេងៗ រួមទាំងអាជីវកម្មផងក្តី ប៉ុន្តែវាឆាប់ពេកណាស់នឹងធ្វើការសន្និដ្ឋានថា ទំនោរខ្ចីប្រាក់កាន់តែច្រើនពីវិស័យផ្លូវការឥឡូវនេះបានរីកទៅដល់ SMEs ។ ហេតុផលមួយក្នុងនេះ គឺកំចីពាណិជ្ជកម្មពីឆ្នាំ២០០៣-២០០៥ ដែលបានរាយការណ៍ឡើង សុទ្ធតែផ្តល់ដោយអេស៊ីលីដា ដែលមានបេសកកម្មគួរឱ្យកោតសរសើរ ប៉ុន្តែខុសគ្នាបន្តិចពីធនាគារពាណិជ្ជឯទៀតៗ ។ ទោះយ៉ាងនេះក្តី មានគេរាយការណ៍បញ្ជាក់ថាយ៉ាងហោចណាស់ក៏មានធនាគារពាណិជ្ជមួយ ដែលបានបង្កើនកំចីបែបនេះចាប់ពីពេលធ្វើអង្កេត រហូតដល់ចុងឆ្នាំ២០០៥ ដោយចាប់ផ្តើមបង្កើនការផ្តល់កំចីសំរាប់ពង្រីក SMEs ។ ជាក់ស្តែងធនាគារ ANZ Royal ដែលជាចំណូលថ្មីក្នុងទីផ្សារធនាគារ ហាក់ដូចមានបំណងនិងអាចផ្តល់កំចីដល់អតិថិជនច្រើនបែបយ៉ាង រួមទាំង SMEs ផងដែរ ។ កំចីទាំងនេះ អាចយកទៅប្រើសំរាប់បើកអាជីវកម្មថ្មី យោងតាមល្បឿនកំណើនទំនុកចិត្តលើស្ថាប័នធនាគារ និងការរក្សាបរិយាកាសឱ្យបន្តអំណោយផលល្អដល់វិស័យអាជីវកម្ម ។

ដោយសារ SMEs ជាប្រភពការងារដ៏សំខាន់ កំណើនចំនួន SMEs រឺការពង្រីកទំហំ SMEs បច្ចុប្បន្ន អាចមានផលប៉ះពាល់ច្រើនណាស់ដល់ចំនួនការងារសរុប ។ ក្នុងនេះ ប័ណ្ណកម្មសិទ្ធិដីអាចក្លាយជាកាតាលីករដ៏សំខាន់ដោយផ្តល់ឱ្យវិនិយោគិននូវអារម្មណ៍កាន់កាប់ដីមានសុវត្ថិភាព និងរបស់សំរាប់ដាក់ធានានៅពេលស្វែងរកកំចីផ្លូវការ សំរាប់បើកអាជីវកម្មថ្មី រឺពង្រីកអាជីវកម្ម ។ ការសន្និដ្ឋាននេះ នឹងយកទៅផ្ទៀងផ្ទាត់បញ្ជាក់ឡើងវិញនៅពេលធ្វើអង្កេតមូលដ្ឋានសំរាប់តាមដានបន្ត ។

## កំណត់សំគាល់

១. ក្នុងការសិក្សាមួយ (Kang 2005) គេបែងចែកសហគ្រាសជា ៣ ប្រភេទ គឺ ធុនមីក្រូ (ប្រើកម្មករ ១-២នាក់) ធុនតូច (កម្មករ ៣-៥នាក់) និងធុនមធ្យម (កម្មករ ១០-១០០នាក់) ។
២. "ពួកគេមានផ្ទះតែគ្មានប័ណ្ណកម្មសិទ្ធិ មានដំណាំតែគ្មានកិច្ចសន្យា មានអាជីវកម្មតែគ្មានលក្ខន្តិកៈ" ។
៣. អង្កេតមិនបានធ្វើនៅខ័ណ្ឌ ៧មករា ទេ ។
៤. សូមអានរបាយការណ៍ប្រចាំឆ្នាំ នៅ www.acledabank.com.kh ។

*សូមមើលឯកសារយោងក្នុងអត្ថបទជាភាសាអង់គ្លេស*